ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥-០២៣-០៤៩០ សជណ

ថ្ងៃចន្ទ ១០រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៣

# សេចក្តីជូនដំណឹង
# ស្តីពី
# ការផ្លាស់ប្តូរយន្តការ និងលក្ខខណ្ឌជាវ មូលបត្រអាចជួញដូរបាន (NCD) ទាំងជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក

ធនាគារជាតិនៃកម្ពុជា មានកិត្តិយស សូមជម្រាបជូន គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មេត្តាជ្រាបថា ធនាគារជាតិនៃកម្ពុជា នឹងផ្លាស់ប្តូរយន្តការ និងលក្ខខណ្ឌជាវមូលបត្រអាចជួញដូរបាន (NCD) ទាំងជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក គ្រប់ឥណប្រតិទាន តាមវិធីសាស្ត្រដេញថ្លៃ (Auction) រៀងរាល់ ២សប្តាហ៍ម្តង។ ការផ្លាស់ប្តូរយន្តការ និងលក្ខខណ្ឌជាវនេះ គឺដើម្បីឆ្លុះបញ្ចាំងពីការកំណត់អត្រាការប្រាក់តាមយន្តការទីផ្សារ ។

ការដាក់ឱ្យដេញថ្លៃ NCD នេះ នឹងចាប់ផ្តើមអនុវត្តនៅថ្ងៃពុធ ១១កើត ខែមាឃ ឆ្នាំខាល ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ ជំនួសឱ្យការចេញផ្សាយ NCD រៀងរាល់សប្តាហ៍ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មេត្តាជ្រាបជាព័ត៌មាន។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧